# អង់តែន

សេង សុខា

ឆ្នាំ១៩៩៨ កញ្ញាបានបញ្ចប់បរិញ្ញាប័ត្រ អក្សរសាស្ត្រខ្មែរ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ បច្ចុប្បន្ន ជាមន្ត្រីរាជការ នៅក្រសួងអប់រំយុវជន និងកីឡា។ នៅ២០០៦នេះ កញ្ញាបានជាប់ចំណាត់ថ្នាក់លេខ១ ពីសមាគមអក្សរសិល្ប៍ន្ធ ហាច ឆ្វែក កំណាព្យ មានចំណងជើងថា អង់តែន។

## Antenna

By Seng Sokha

ទូរទស្សន៍មិនច្បាស់ម្ចាស់ខឹងម៉្វា
ទោសៈមោហាបាត់វៃក្វែន
ឡើងដំបូលផ្ទះក្តាប់យ៉ាំងណែន
បង្វិលអង់តែនរាវទិសា។
បែកញើសគឃៀរលាន់មាត់ប៉ែ!
អង់តែនចង្រៃពិតអសារ
សូររូបត្រួតគ្នាមើលយ៉ាំងណា
បង្វិលទៅមកបួនដប់ជុំ
ផ្លាស់ប្តូរអង់តែនចោលជាម្តង
ពុំតែផ្ទះមួយស្មើរសព្វដី
បង្វិលផ្លាស់ប្តូរអង់តែនផ្តាស
រូបពុំច្បាស់ម្ចាស់ដាក់កំហុស
អង់តែនតាមផ្ទះម្ចាស់កម្ចាយ
មនុស្សថែអង់តែនផ្សាយទូរទស្សន៍
ចំណែកទូរស័ព្ទរឹតសង្ហា
លាបលនថ្នាំព័ណ៌គួរគយគន់
បំពាក់ឧបករណ៍ល្អប្រណីត
អង់តែនខាំងផ្សាយគ្មានចំបែង
ទោះរូបសូរស័ព្ទខ្វ័ររំខាន
រីអង់តែនតូចឈរប្រូងប្រាង
មូលជ្រុងវែងខ្វីចងក្រៀកកល់
ហាលថ្ងៃភ្លៀងខ្យល់ទឹកសន្សើម
ជាតិអង់តែនតូចៗគ្រប់ទី
ធ្វើទុក្ខសោតានិងភ្នែកផង។
កំហឹងផ្ទុះធំគួចគិតប៉ង
ក្រែងដូចបំណងរូបប្រែច្បាស់។
នាំគ្នាឃ្មាតខ្មីទាំងក្មេងចាស់
ភ្លេចគិតស្រឡះអង់តែនផ្សាយ។
តិះដៀលបន្ទុះដេរដល់ម្តាយ
អង់តែនខាំងផ្សាយពេញហ៊ឹហា។
វិទ្យុធំខ្ពស់កប់វេហាស៍
ផ្សាយគ្រប់ទិសាដំឡើងឫទ្ធិ។
ស្អិតស្អាងលើសលន់ឆើតវិចិត្រ
ទីខ្ពស់ពេកពិតសែនថ្កើងថ្កាន។
រាំងរៅខែងរ៉ែងសុខក្សេមក្សាន្ត
រាល់មនុស្សពុំបានទឹកគិតដល់។
ប្រវេងប្រវាំងលាយច្របល់
ក្រវាយក្រវល់ស្នឹមច្រែះស៊ី។
រន្ធះគួរស្ញើមញ៉រធរណី
ត្រូវមនុស្សយាយីឥតស្រាកស្រាន្ត។

អង់តែនលោហៈដូចតែគ្នា
ហេតុអ្វីមនុស្សម្នាតាមរំខាន
ដូចស្រមោលអន្ទោលតាមប្រាណ
អង់តែនតូចបានត្រឹមបង្ខិល។
អង់តែនខ្លះចងនឹងដើមឈើ
ខ្លះដាក់បន្ទើរហាលសំដិល
លើដំបូលផ្ទះពុករេចរឹល
រលំដួលត្និលបាក់គ្រេចបង់។
ឯអង់តែនធំសែនស្កឹមស្កៃ
ទោះបីហាលថ្ងៃរឹងមាំត្រង់
ឈរលើគ្រឹះថ្មរបងសង់
ការពាររហង់មនុស្សថែថ្នម។
តុបតែងថ្នមថ្នាក់ឥតអាក់ខាន
អង់តែនធំបានសុខស្រួលខ្លួន
ផ្គរលាន់រន្ទះពុំរុករួន
ខ្យល់ប្រឹងអង្រួនឥតបានការ។
ទោះជាមានភ្លៀងធ្លាក់ចម្លែក
ដូចគេចាប់ហែកអាកាសា
ព្យុះសង្ឃរាបក់ខ្លាំងអស្ចារ្យ
រលំសព្វសារពើរបស់។
អង់តែនតូចៗផងទាំងឡាយ
បាក់ប៊ើងខ្ទាត់ខ្ចាយវិនាសអស់
សល់អង់តែនធំឈរចន្លោះ
ពុំរលំសោះបន្តផ្សាយ។
ភ្លឹបភ្លែតកោកៗថ្លែងសេចក្តី
ព័ត៌មានវែងខ្លីពីជិតឆ្ងាយ
មនុស្សផងទាំងពួងក្តៅក្រហាយ
ក្នុងចិត្តនឿយណាយដូចខ្វាក់ថ្លង់។
គ្មានរូបសួរ ព្រោះអង់តែនតូច
រលំដួលខូចវិនាសបង់
មនុស្សយល់ហេតុការណ៍ឥតបង្អង់
លើកពត់តម្រង់អង់តែនវិញ។
រូបភាពសួរស័ព្ទប្រែប្រក្រតី
មួយរំពេចខ្ចីក្លាយទៅម្នេញ
អង់តែនផ្សាយពុំចប់ពេញលេញ
ស្រវាស្រទេញឥតប្រយោជន៍។
ប្រភពថាមពលអគ្គិសនី
នៅឯស្ថានីយផ្ទុះឆេះខ្ទោច
អង់តែនធំផ្សាយខូចហិនហោច
របេះរបោចធ្លាក់ដល់ដី។
រីឯអង់តែនតូចទាំងឡាយ
គ្មានអង់តែនផ្សាយប្រែឥតន័យ
ទោះប្រឹងបង្ខិលទិនរាត្រី
មិនអាចលកលៃស្រូបទទួល។
នាទីអង់តែនធំនិងតូច
ពុំអាចប្រដូចតាមជ្រើមជ្រួល
បើធំរឹងមាំឯតូចដួល
កើតក្តីមិនស្រួលសែនឯកា។
ការផ្សាយរសាត់ទៅតាមខ្យល់
ពុំជ្រួតជ្រាបដល់ចេញផ្លែផ្កា
ខាងទទួលគ្មានបេះតែថា
សម្បកសង្ហាខ្លឹមសារគ្មាន។
ប្រសិនបើតូចនៅបិតថេរ
ខាងផ្សាយធំមេដេកក្រវៀន

ដាក់កម្លាំងផ្សេងចូលទន្ទ្រាន ត្រួតត្រាឈ្នានពានច្រួលច្របល់។
ជាតិអង់តែនធំជាពំនឹង អង់តែនតូចពឹងដោះកន្ទល់
អង់តែនតូចពិតទីតម្កល់ អង់តែនធំថ្កល់នឹងថេរបិត។
អង់តែនតូចធំអាស្រ័យគ្នា ខ្លាំងក្លាមហិមាមានតេជឫទ្ធិ
ទោះភ្លៀងរន្ទះព្យុះងងឹត ចាកផុតភ័យភិតគ្រប់វេលា៕